ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
សាខាពន្ធដារខេត្តឧត្តរមានជ័យ
លេខ...២៩៤២....អពដ.សខ.ឧជ

ឧត្តរមានជ័យ,ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៤

## លិខិតជូនដំណឹង

### ជម្រាបមក

លោក-លោកស្រីម្ចាស់ទីតាំងលក់ដុំ-លក់រាយបារីគ្រប់ប្រភេទ ភោជនីយដ្ឋាន ក្លឹបកំសាន្ត ខារ៉ាអូខេ

**កម្មវត្ថុ÷** ស្តីពីការរំលឹកការបិទតែមប្រើអាករសម្រាប់បារីគ្រប់ប្រភេទ ។

**យោង ÷** -ច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧
-លិខិតលេខ ១៤០៦ អពដ ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៤ របស់អគ្គនាយកដ្ឋានពន្ធដារ ។

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុ និង យោងខាងលើ សាខាពន្ធដារខេត្តសូមជូនដំណឹងដល់លោក-លោកស្រីម្ចាស់ទីតាំងលក់ដុំ-លក់រាយបារីគ្រប់ប្រភេទ ភោជនីយដ្ឋាន ក្លឹបកំសាន្ត ខារ៉ាអូខេ ក្នុងខេត្តឧត្តរមានជ័យទាំងអស់ឱ្យបានជ្រាបថា លោក-លោកស្រីត្រូវបិទតែមប្រើអាករសម្រាប់បារីគ្រប់ប្រភេទ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ ។ ករណីមិនបានបិទតែមប្រើអាករ ឬ បិទតែមប្រើអាករក្លែងក្លាយ ឬ បិទតែមប្រើអាករបានប្រើប្រាស់រួច ឬ បិទតែមប្រើអាករមិនត្រឹមត្រូវ ត្រូវទទួលរងទោសទណ្ឌពីច្បាប់ស្តីពីសារពើពន្ធជាធរមានដូចខាងក្រោម ÷

១-ត្រូវទទួលពិន័យចំពោះអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ២.០០០.០០០៛(ពីរលានរៀល)ឬជាប់ពន្ធនាគារពី ១ខែ ដល់ ១ ឆ្នាំ ឬ ទោសទាំងពីរ ។

២-ត្រូវទទួលពិន័យចំពោះអ្នកជាប់ពន្ធតាមរបបម៉ៅការ ៥០០.០០០៛(ប្រាំរយពាន់រៀល) ឬជាប់ពន្ធនាគារពី ១ខែ ដល់ ១ ឆ្នាំ ឬ ទោសទាំងពីរ ។

បន្ទាប់ពីបានចែកលិខិតជូនដំណឹងនេះយ៉ាងយូរមួយខែ សាខាពន្ធដារខេត្តនឹងចាត់មន្ត្រីចុះត្រួតពិនិត្យការបិទតែមប្រើអាករសម្រាប់បារីដល់ទីតាំងលក់ដុំ-លក់រាយបារីគ្រប់ប្រភេទ ភោជនីយដ្ឋាន ក្លឹបកំសាន្ត ខារ៉ាអូខេ ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច (មន្ត្រីនគរបាល និង មន្ត្រីកងរាជអាវុធហត្ថ) ។

សាខាពន្ធដារខេត្តឧត្តរមានជ័យ សង្ឃឹមជឿជាក់ថាបងប្អូនជាអាជីវករទាំងអស់ ប្រាកដជាសហការ និង អនុវត្តកាតព្វកិច្ចបិទតែមប្រើអាករសម្រាប់បារីគ្រប់ប្រភេទ តាមច្បាប់ស្តីពីសារពើពន្ធជាពុំខានឡើយ ។

សូមលោក-លោកស្រីម្ចាស់ទីតាំងលក់បារីទាំងអស់ ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅអំពីយើងខ្ញុំ ។

ប្រធានសាខាពន្ធដារខេត្ត

ជុំ សំនិត

**ចម្លងជូន÷**
- អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្តឧត្តរមានជ័យ
- សាលាខេត្តឧត្តរមានជ័យ
- ស្នងការដ្ឋាននគរបាលខេត្តឧត្តរមានជ័យ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តឧត្តរមានជ័យ
  (ដើម្បីគោរពជូនជ្រាប)
- ឯកសារ-កាលប្បវត្តិ

អគារខាងលិចសាលាខេត្ត ទល់មុខវិមានឯករាជ្យ ភូមិឈូក សង្កាត់សំរោង ក្រុងសំរោង ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ:(855) 65 63 58 168,E-mail: odormeanchey@tax.gov.kh, Website: www.tax.gov.kh